# សិក្ខាសាលាស្តីពី "ភាពជាអ្នកដឹកនាំ"

កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទដែលមានឈ្មោះថា **"សិស្សអ្នកដឹកនាំសហគមន៍វ័យក្មេង"** បានចាប់ផ្តើមតាំងពីឆ្នាំ ២០០៦ មកដោយកម្មវិធីរៀបចំឡើងក្នុងគោលបំណងចម្បងឱ្យយុវជនមានឱកាសបង្កើនសមត្ថភាពរបស់ខ្លួនដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ជនបទ និងមានអាជីពមួយពិតប្រាកដនៅជនបទតាមរយៈការសិក្សារៀនសូត្រជាទ្រឹស្តី និងការចុះអនុវត្តក្នុងការសម្របសម្រួលជាមួយកសិករ និងជាមួយបុគ្គលិកសេដាកនៅតាមខេត្តគោលដៅ ។ ចំពោះកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកសហគ្រិនកសិកម្មដែលមានឈ្មោះថា **"ការអភិវឌ្ឍន៍ និងគ្រប់គ្រងសហគ្រាសកសិកម្ម"** បានចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៨ ដោយកម្មវិធីរៀបចំឡើងក្នុងគោលបំណងចម្បងឱ្យយុវជនជនបទមានអាជីពកសិកម្មមួយច្បាស់លាស់ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ជនបទ ។

គិតមកដល់ខែធ្នូ ឆ្នាំ ២០០៨ កម្មវិធីសិស្សអ្នកដឹកនាំសហគមន៏វ័យក្មេង បានរៀបចំនឹងកំពុងពង្រឹងសមត្ថភាពដល់យុវជនជនបទ សរុប ២៤១ (ស្ត្រី ៨០ នាក់) ដែលមិនមានឱកាសដើម្បីទៅរៀនសូត្របន្តបាន (អ្នកដែលធ្លាក់ ឬជាប់បាក់ឌុប ជាកូនកសិករ) នៅក្នុងខេត្តចំនួន ១៧ ។ ចំពោះកម្មវិធីការអភិវឌ្ឍន៍ និងគ្រប់គ្រងសហគ្រាសកសិកម្ម យើងបានធ្វើការបណ្តុះបណ្តាលដល់សិស្សចំនួន ១០០ នាក់ (ស្ត្រី ២៨ នាក់) ហើយនឹងគ្រោងពង្រីករហូតដល់ ១៣០ នៅចុងឆ្នាំ ។



សិក្ខាសាលារយៈពេល ២ ថ្ងៃ គឺនៅថ្ងៃទី ១៥-១៦ ខែធ្នូ ឆ្នាំ ២០០៨ ស្តីពី "**ភាពជាអ្នកដឹកនាំ**" ត្រូវបានប្រារព្ធធ្វើឡើងដោយអង្គការសេដាក នៅសាលប្រជុំរបស់វិទ្យាស្ថានជាតិអប់រំ ស្ថិតនៅមហាវិថីព្រះនរោត្តម ជិតវិមានឯករាជ្យ និងដោយទទួលបានការឧបត្ថម្ភពីមូលនិធិហ្វ្រីឌ្រិច ណៅម៉ាន់ គម្រោង PRS-EU គម្រោងសន្សំប្រាក់ ដើម្បីភាពអាស្រ័យខ្លួនឯង គម្រោងកែលំអកម្រិតជីវភាពកសិករក្រីក្រ នៅស្រុកកំពង់ត្រឡាច គម្រោង SCLP-VPS និងកម្មវិធីសិស្ស សហគ្រិនកសិកម្ម (ESP និង HEKS) ។ សិក្ខាសាលានេះរៀបចំឡើង ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ចន្ទ័ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថ្នាក់ដឹកនាំមួយចំនួនរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសិស្ស អ្នកដឹកនាំសហគមន៏វ័យក្មេង ព្រមទាំងសិស្សសហគ្រិនកសិកម្មសរុបទាំងអស់ចំនួន ២២៣ នាក់ ។